# ទស្សនវិទូ ហ្សេណុង

## Zenon

ហ្សេនណុង ជាកូនប្រុសរបស់Mnaséas( ឬ Déméo)មានដើមកំណើតមកពីCitiumដែលជាទីក្រុងមួយនៅកោះ Chypre,ជាបន្ទាយរបស់ជនជាតិ Hellènes (Grecs)ប៉ុន្តែកាន់កាប់ដោយក្រុមជនជាតិPhéniciens។លោកមានកធំ។ Appolonios បាននិយាយថា លោកមានមាឌធំតែស្គមហើយស្បែកសំបុរសណ្តែកបាយដែលនាំអោយគេអោយរហ្សសនាមថាដើមតាលព្រឹក្សអេហ្ស៊ីប(ដើមត្នោតអេហ្ស៊ីប)។លោកមានកំភួនជើងធំៗ តែដងខ្លួនស្បែកយៀកសាច់ជ្រាយហើយកំលាំងខ្សោយ។ហេតុដូច្នេះហើយបានជាគេកំរឃើញលោកអញ្ជើញទៅចូលរួមពិធីជប់លៀងណាស់។តាមការដឹងឮតមកថា ៖លោកចូលចិត្តញ៉ាំផ្លែល្វា ស្រស់ឬហាលក្រៀម។ លោកគឺជាសាវ័ករបស់Cratès។ដើមឡើយលោកធ្វើជាសាវ័ករបស់ Stilpon ហើយ និងXenocrate អស់រយ:ពេលដប់ឆ្នាំ។ទីបញ្ចប់លោកក៏បានមកតោង ក្រាតទែរវិញ។លោកបរិភោគអាហារបន្តិចបន្តួច,ដូចជានំប៉័ង ហើយនិងទឹកឃ្មុំ និងផឹកស្រាទំពាំងបាយជូរឆ្ងាញ់តែបន្តិចបន្តួចប៉ុណ្ណោះ។លោកគ្មានស្រីកំណាន់អីទេ ហើយបើទៅលេងស្រីពេស្យាម្តងឬពីរដង ក៏ដើម្បីកុំអោយគេមើលមកថាលោកគឺជាមនុស្សស្អប់ខ្ពើមស្រី(Misogyne)តែប៉ុណ្ណោះឯង។លោករស់នៅក្រោមដំបូលផ្ទះជាមួយPerséeដែលថ្ងៃមួយបាននាំស្រីម្នាក់ចេះផ្លុំខ្លុយមក,ប៉ុន្តែលោកច្រានចេញយ៉ាងលឿន។លោកគឺជាមនុស្សដែលមានការរាក់ទាក់ជាទីបំផុត ទាល់តែAntigonបានអញ្ជើញលោកអោយមកចូលរួមពិធីជប់លៀងរបស់ខ្លួនហើយមានថ្ងៃមួយថែមទាំងបាននាំគ្នា(បបួលគ្នា)ទៅចូលរួមពិធីជប់លៀងនៅផ្ទះAristoclèsជាអ្នកប្រគុំពិនក្រិកទៀតផង។ ប៉ុន្តែក្រោយមក,លោកក៏រស់នៅដាច់ឆ្ងាយពីគេដោយមកពីមិនចូលចិត្តនៅក្បែរហ្វូងមនុស្ស(la foule)។ លោកទំលាប់អង្គុយលើបង់ខាងចុងឆ្ងាយ ។ធ្វើដូច្នេះ គឺលោកអាចគេចការរំខានបានពាក់កណ្តាលទៅហើយ ។លោកមិនដែលដើរលេងមានគ្នាលើសពីពីរឬបីនាក់ឡើយ។ជួនកាលលោកថែមទាំងបានសូមប្រាក់នរណាក៏ដោយដែលមកជិតលោក ដើម្បីកុំអោយរំខានពីមនុស្សច្រើនពេក។លោកមានទឹកមុខក្រៀមស្រពោន និងជូរចត់ហើយមានថ្ពាសជ្រួញ។លោកស្លៀកកពាក់យ៉ាងសាមញ្ញបំផុត ហើយ ដោយយកលេសថាសំចៃ ក៏ចេះតែសំចៃដូចមនុស្សមិនស៊ីវិល័យ។បើត្រូវជាបន្ទោសនរណាម្នាក់,លោកបន្ទោសតែមួយភ្លែត ហើយក៏មិនដែលជ្រុលឡើយ។លោកនិយាយថា គ្មានអីចំលែកទៀតទេចំពោះការបានរៀនសូត្រចេះដឹងពីវិទ្យាសាស្រ្តជាងជំនឿសាសនា ហើយថាគ្មានអីចាំបាច់សំរាប់មនុស្សលោកជាងពេលវេលាឡើយ។ មានមនុស្សម្នាក់បានសួរទៅលោកថា ៖តើដូចម្តេចហៅថាមិត្ត? លោកក៏ឆ្លើយតបថា៖គឺខ្លួនខ្ញុំម្នាក់ទៀត។ ទាសីលោកម្នាក់បានប្រព្រឹត្តចោរកម្ម,លោកបានវាយគេនឹងរំពាត់។ទាសីម្នាក់ទៀតបានប្រាប់ទៅលោកថា៖វាជាវាសនារបស់ខ្ញុំដែលបានជំរុញខ្ញុំអោយធ្វើចោរ_ អើ,ចឹងក៏ជំរុញអោយត្រូវរំពាត់ដែរ!លោកឆ្លើយតប។ លោកនិយាយថា៖សម្ផស្សគឺជាផ្លែផ្កានៃគតិបណ្ឌិត តែតាមអ្នកផ្សេងទៀតវិញថាគតិបណ្ឌិតគឺជាផ្លែផ្កានៃសម្ផស្ស។ លោកបាននិយាយទៅកាន់មនុស្សម្នាក់ដែលជាមនុស្សនិយាយច្រើនថា៖ យើងមានត្រចៀកពីរ និងមាត់តែមួយក៏ព្រោះថាយើងរត្រូវតែស្តាប់ច្រើនជាងនិយាយ ។មានមនុស្សម្នាក់បានចោទសួរលោកថា៖ហេតុអ្វីលោក ជាមនុស្សម៉ឹងមាត់ចេះលេងសើចអីដែរក្នុងពេលជប់លៀង?លោកឆ្លើយតបទៅថា៖ សណ្តែករឹងខ្លាំងណាស់ប៉ុន្តែពេលណាគេដាក់ត្រាំទឹក ក៏វាចេះទន់ដែរ!លោកបានទទួលមរណភាពនៅជន្មាយុ៩៨ឆ្នាំ ដោយមិនដែលមានជំងឺព្យាធិឡើយ។Perséeក្នុង«សៀវភៅនិកាយសីលធម៌»របស់លោកបានប្រាប់ថា លោកហ្សេនណុងស្លាប់នៅអាយុ៧២ឆ្នាំ ហើយថាលោកបានមករស់នៅទីក្រុងអាតែន នៅអាយុ២២ឆ្នាំ។ប៉ុន្តែAppollonios បានអះអាងថា៖លោកគ្រប់គ្រងសាលារៀនអស់រយ:កាល៥៨ឆ្នាំ។ខាងក្រោមនេះ គឺឧប្បត្តិហេតុដែលកើតឡើងមុនពេលលោកកំពុងនឹងទទួលមរណភាព៖ ចាកចេញពីសាលារបស់លោក,ស្រាប់តែលោកដួលហើយបាក់ម្រាមដៃមួយ,ប៉ុន្តែយកដៃទះដីផាំងៗរួចសូត្រកាព្យមួយរបស់Niobéមានសេចក្តីដូចនេះ៖ Jeviens, pourquoi m`appelles-tu? ដែលប្រែថា៖ ខ្ញុំមកហើយតើ,ម្តេចឯងហៅខ្ញុំធ្វើអី?ហើយភ្លាមនោះលោកក៏ដាច់ដង្ហើមទៅ។តាមការស្រាវជ្រាវបានអោយដឹងថា ឪពុកលោក Mnaséasជាឈ្មួញលក់ដូរហើយបានទិញសៀវភៅជាច្រើនគឺសៀវភៅដែលសរសេរគំនិតរបស់សូក្រាត ,ទុកអោយកូនតូចហ្សេនណុងអាន។តាំងពីនោះមក,ក្មេងហ្សេនណុងក៏ចាប់ផ្តើមចាប់អារម្មណ៍នឹងទស្សនវិជ្ជារួចហើយក៏មកតោងលោកក្រាតែទែរ សុំធ្វើជាសាវ័ក។